១១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៧/៤

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៩១៥

ចុះថ្ងៃទី ១៤-៦-២០១០

សាលដីការបៀប

លេខៈ ០៣ ក្រ ប ស-

ចុះថ្ងៃទី ២៧-៧-២០១១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បង្កើតឡើង តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ១៤-៧-២០១១ ដែលមានសមាសភាពដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ ៩១៥ ចុះថ្ងៃទី១៤-៦-២០១០ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីលក់ដូរ កើតនៅភូមិចុងខ្លង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ មានទីលំនៅបច្ចុប្បន្នភូមិចុងខ្លង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted]) ប្រពន្ធ [redacted] នកូន ០១នាក់ ទោសពីមុន-គ្មាន ។

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ជាតិខ្មែរឥស្លាម កើតនៅភូមិត្រពាំងខ្លង ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ចាម មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ននៅភូមិចុងខ្លួយ ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted] មានកូន ៧នាក់ ទោសពីមុនគ្មាន ។

-ជនជាប់ចោទទាំងពីរមានដោយលោ [redacted] ជាមេធាវីការសិទ្ធិជនជាប់-ចោទ ។



Scanned by CamScanner

<u>ជាប់ចោទពីបទ:</u> មនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ភេទស្រី អាយុ ៥០ឆ្នាំ ជាតិខ្មែរ នៅភូមិក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ ។

## <u>៦រឿងហេតុមានដូចតទៅ</u>

**សកម្មភាព** ប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ៖

កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោ[redacted]បានធ្វើដំណើរមកពីលេខផ្ទះកូននៅភូមិចុងខ្លង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ដោយជិះម៉ូតូលើកំណាត់ផ្លូវជាតិលេខ ៥ ឆ្ពោះមកទីរួមខេត្តពោធិសាត់ ។ លុះមកដល់ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិ៍សាត់ នៅវេលាម៉ោង១១ និង ៣០នាទី មានជនល្មើសចំនួន ០២នាក់ ជិះម៉ូតូឌុបគ្នាមកតាមក្រោយដល់កៀកបានបាញ់ជនរង-គ្រោះ នឹងកាំភ្លើងខ្លី ១គ្រាប់ ត្រូវក្រោមឆ្អឹងជំនីខាងឆ្វេងបណ្តាលឲ្យរបួសធ្ងន់ និងបណ្តាលឲ្យស្លាប់ក្រោយពីបានសង្គ្រោះនៅមន្ទីរពេទ្យ ។

**ច្បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: ០៤ "ជ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ឲ្យឈ្មោ[redacted]ខ្លួនពីបទចោទ <u>ពីបទ</u> មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទំងន់ ទោសនៃបទឧក្រិដ្ឋ ។

២-លើកចោលការប្តឹងទាមទារជម្ងឺចិត្ត របស់អ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]នួន ១០.០០០ (ដប់ពាន់) ដុល្លាអាមេរិក ពីជនជាប់ចោទ [redacted]ដោយខុសទៅនឹងគតិច្បាប់ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចំពោះមុខជនជាប់-ចោទ និងអ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ច្បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ[redacted] តំណាងអយ្យការ សុំប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ: ០៤ "ជ" ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ទាំងមូលនៃសាលក្រម



Scanned by CamScanner

**ឃ្មានឃើញ** របាយការណ៍សំណុំរឿងព្រហ្មទណ្ឌលេខៈ ៨១៥ ចុះថ្ងៃទី ១៨-៦-២០១០ របស់ចៅក្រមរបាយការណ៍ នៃសាលាឧទ្ធរណ៍ ។ 7½

**ឃ្មានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ២២-១២-២០១០ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាអានសង្ខេបរបាយការណ៍រឿងក្តី ។

-ជនជាប់ចោទឈ្មោះ[redacted] (អវត្តមាន)

-ជនជាប់ចោទឈ្មោះ[redacted] (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] (អវត្តមាន)

-មេធាវីការពារជនជាប់ចោទឈ្មោះ[redacted] (វត្តមាន)

(អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]

ប្រធានក្រុមប្រឹក្សាអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមការស្នើសុំរបស់តំណាងមហាអយ្យការ ។

## សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

អយ្យការអមតុលាការខេត្តពោធិ៍សាត់ ចោទប្រកាន់ពីបទមនុស្សឃាត ដូចនេះតំណាងអយ្យការស្នើសុំចោទប្រកាន់លើជនជាប់ចោទរូបនេះ តាមសេចក្តីសន្និដ្ឋានរបស់មហាអយ្យការ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-មេធាវីការពារលោក[redacted]ឆ្លើយការពារថាៈ ហេតុដលចោទប្រកាន់លើកូនក្តីខ្ញុំគឺដើមបណ្តឹងដឹងលឺតាមគេប្រាប់ប៉ុណ្ណោះ ភស្តុតាងនិងកោសលវិច័យគឺគ្មានឡើយ ជនរងគ្រោះក៏ពុំបានឃើញមុខកូនក្តីខ្ញុំឡើយ គឺជនរងគ្រោះ និងជនជាប់ចោទ នៅថ្ងៃកើតហេតុមានទីកន្លែងនៅដាច់ផ្សេងពីគ្នាទេ ហើយចម្លើយសាក្សីក៏ឆ្លើយថាឈ្មោះ[redacted] នៅផ្ទះទេ ពេលកើតហេតុនោះ រ[redacted] នៅហាងផឹកកាហ្វេនៅម៉ោង ១១ ព្រឹក ហើយមានប្រជាពលរដ្ឋជាង ២០០ នាក់ ផ្តិតមេដៃគាំទ្រថាឈ្មោះ[redacted] មនុស្សល្អ មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គ្រាន់តែជាមិតិសង្ស័យប៉ុណ្ណោះ សុំតម្កល់សាលក្រមទុកជាបានការ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់ ។



Scanned by CamScanner

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោ[redacted] ជាតំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ ។

២-នាពេលសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សាយ គង់ ជាប្រពន្ធជនរងគ្រោះ បានបញ្ជាក់ថា មុនពេលប្តីគាត់ស្លាប់បាននិយាយប្រាប់ប៉ូលីសថា អ្នកបាញ់សំលាប់គាត់គឺមានឈ្មោ[redacted]និងឈ្មោ[redacted]ន្តែមានសាក្សីឈ្មោ[redacted] និងឈ្មោះ [redacted]ជាមន្ត្រីនគរបាលបានបញ្ជាក់ថា នៅថ្ងៃកើតហេតុ ពេលម៉ោងប្រហែល ១១ និង ៣០នាទី ជនជាប់ចោទនៅជាមួយខ្លួន ។

៣-ដើម្បីមានមូលដ្ឋានច្បាស់លាស់ ថាតើជនជាប់ចោទមានមុខនៅកន្លែងគុកាហ្វេ និងនៅព្រះវិហារឥស្លាម នៅវេលាណាច្បាស់លាស់ រយៈពេលធ្វើដំណើរពីកន្លែងកើតហេតុមកកន្លែងផឹកកាហ្វេ ដែលសាក្សីបានអះអាង ត្រូវចំណាយពេលប៉ុន្មាន គប្បីធ្វើការស៊ើបសួរបន្ថែម ដោយយោងតាមមាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១-ស៊ើបសួរបន្ថែមនូវៈ

-ពេលវេលាដែល ជនរងគ្រោះត្រូវគេបាញ់សំលាប់

-ពេលវេលាផ្សេងៗទៀតរបស់ជនជាប់ចោទ និងសាក្សី ដែលបានឃើញហេតុការណ៍ និងសាក្សី ដែលនៅជាមួយជនជាប់ចោទ ។

-សាកសួរលើឈ្មោះ[redacted]ាន្តនគរបាលនៃអធិការដ្ឋានក្រុងពោធិ៍សាត់ ពីពេលវេលា ដែលអ្នកទាំងពីរបានកសាងក្នុងកំណត់ហេតុ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី 03 ខែ 10 ឆ្នាំ២០១១

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]